


## បណ្ដាញសម្រាប់ជោគជ័យ

គន្លឹះសំខាន់មួយដើម្បីធ្វើឲ្យមានជោគជ័យជានិរន្ត នៅសាលាដែលមានស្ថានភាពលំបាក គឺសមត្ថភាព បង្កើត និង ប្រើប្រាស់ បណ្ដាញគាំទ្រ។ ជាមាតាបិតា សិស្សានុសិស្ស គ្រូបុគ្គលិកជំនួយ និង រដ្ឋបាល យើងមិនរស់នៅ និង ធ្វើការតែឯកឯងនោះទេ – មានមនុស្សនៅជុំវិញយើងដែលអាចជួយយើង និង អាចទទួលប្រយោជន៍ពីការគាំទ្ររបស់យើង។ យើងអាចរៀនពី ចំណេះដឹង និង ជំនាញ ពីគ្នាទៅវិញទៅមក រៀនពីរបៀបដែលអ្នកដទៃដោះស្រាយស្ថានភាពស្រដៀងគ្នា ឬស្វែងរកឱកាសដែលស្រដៀងគ្នា យើងអាចចែករំលែកព័ត៌មាន ផ្ដល់ជំនួយ និងផ្ដល់ការលើកទឹកចិត្ត និងជួយសម្រួលដល់គ្នា នៅក្នុងស្ថានភាពដ៏លំបាក។ បណ្ដាញជំនួយ ជួយបង្កើនគុណភាពនៃជីវិតរស់នៅរបស់យើង និងជួយពង្រីកទំនាក់ទំនង ផ្ទាល់ខ្លួន និងសម្រាប់អាជីព របស់យើង អាចឲ្យយើងសម្រេចនូវលទ្ធផលដែលយើងមិនអាចសម្រេចបានតែឯង។

ដូចគ្នានេះដែរ បណ្ដាញទំនាក់ទំនងមានសារៈសំខាន់សម្រាប់បុគ្គលម្នាក់ៗ ហើយក៏មានសារៈសំខាន់សម្រាប់អង្គការនានាដែរ។ ជាសំណាងល្អ មិនថាសាលារបស់លោកអ្នកស្ថិតនៅទីណានោះទេ គឺតែងតែមានមនុស្សនៅក្នុងសហគមន៍របស់លោកអ្នក និងអ្នកនៅកន្លែងផ្សេងទៀត ដែលមានឆន្ទៈដើម្បីជួយ និងគាំទ្រសាលា របស់លោកអ្នក នាំយកកម្មវិធី ចែករំលែកជំនាញ និងផ្ដល់ជំនួយផ្សេងៗ ដល់សាលា។ ក្រុមប្រឹក្សាសាលាអាចដឹកនាំការស្រាវជ្រាវ និងកត់សម្គាល់កន្លែងដែលមានជំនួយ ធ្វើទំនាក់ទំនង និង អភិវឌ្ឍការសហការគ្នា។ តាមការណែនៃទស្សនៈវិស័យរបស់សាលា និងផែនការអនុវត្តដែលសាលាបានបង្កើតឡើង ក្រុមប្រឹក្សាសាលាបានរៀបចំឡើងដើម្បីជាយុទ្ធសាស្ត្រ ក្នុងការបង្កើតការសហការគ្នា ដើម្បីគាំទ្រចំណុចទាំងពីរនេះ ជួយបន្តការដោះស្រាយបញ្ហា ដែលត្រូវនឹងសេចក្តីត្រូវការរបស់សាលា។

### គណៈកម្មាធិការកែទម្រង់សាលារៀន

**ប្រធាន**
Pedro A. Ramos

**សមាជិក**
Joseph A. Dworetzky
Feather Houstoun
Wendell E. Pritchett
Sylvia P. Simms

### ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

**អគ្គនាយកក្រសួងអប់រំ**
William R. Hite Jr.

**នាយិកា នៃការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍**
Evelyn Sample-Oates

**អ្នកចាត់ចែងកម្មវិធី សម្រាប់ក្រុមប្រឹក្សាសាលា**
Julia Manokhina

**ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ក្រុមប្រឹក្សាសាលា សូមមើល វិបសៃ www.philasd.org/sac, អ៊ីមែល sac@philasd.org ឬ ទូរស័ព្ទ ២១៥-៤០០-៤១៨០។**

បើសិនជាលោកអ្នកចង់ចូលរួមជាសមាជិកនៃក្រុមប្រឹក្សាសាលា សូមបំពេញលិខិតជ្រើសរើសបេក្ខជនឲ្យឈរ ឈ្មោះសម្រាប់ ក្រុមប្រឹក្សាសាលា តាមអ៊ិនធ័រណិត ឬ សុំ ច្បាប់ចម្លងនៃលិខិតនេះ ពីសាលារបស់លោកអ្នក។ បើសិនជាបច្ចុប្បន្ននេះក្រុមប្រឹក្សាសាលារបស់លោកអ្នកមិនទទួលសមាជិកថ្មី សូមសាកសួរអំពីអង្គប្រជុំរបស់ក្រុមប្រឹក្សាសាលានៅថ្ងៃក្រោយ ហើយសូមអញ្ជើញមកចូលរួមជាភ្ញៀវ។ លោកអ្នកអាចដាក់លិខិតជ្រើសរើសបេក្ខជនឲ្យឈរ ឈ្មោះ ហើយអាចឈរឈ្មោះសម្រាប់ការបោះឆ្នោតនៅឆ្នាំសិក្សាក្រោយ។

*Translation and Interpretation Center (9/2014)*

Office of **Family And Community Engagement**
*The FACE of the School District of Philadelphia*



ឲ្យគេរាប់បញ្ចូលយោបល់របស់លោកអ្នក!

ចូលរួមជាមួយ

# {SAC}

## ក្រុមប្រឹក្សាសាលា

**ក្រុមប្រឹក្សាសាលា =**

- ទស្សនៈវិស័យ
- សាមគ្គីភាព
- ការប្ដេជ្ញា
- ការឆ្នៃប្រឌិត
- លទ្ធផល

**ឱកាសធ្វើឲ្យសាលារបស់លោកអ្នកកាន់តែប្រសើរឡើង**

**www.philasd.org/sac**



## តើ ក្រុមប្រឹក្សាសាលា ជាអ្វី?

ក្រុមប្រឹក្សាសាលា (SAC) គឺជាក្រុមប្រឹក្សាដែលធ្វើយ៉ាងណាឲ្យមានអ្នកតំណាងទូទាំងសាលា នៅពេលពិភាក្សាអំពីរឿងផ្សេងៗ និង ធ្វើការ សម្រេចចិត្តទាំងឡាយ ដែលប៉ះពាល់ដល់សាលាទាំងមូល។

ក្រុមប្រឹក្សាសាលា សូមអញ្ជើញអ្នកសំខាន់ៗ ទាំងអស់ឲ្យផ្តល់គំនិតយោបល់ ដែលអាចជួយធ្វើឲ្យសាលាជាកន្លែងដ៏ល្អប្រសើរ សម្រាប់សិស្សានុសិស្សទាំងអស់។ ការផ្តល់ឲ្យមានគណកម្មការដើម្បីបញ្ចេញមតិយោល់ សម្រាប់ការយល់ឃើញខុសៗគ្នានេះ ក្រុមប្រឹក្សាសាលា ក្លាយជាវេទិកាសម្រាប់ ការពិភាក្សា និង ការសហការ រវាង សមាជិកនៅក្នុងក្រុម និង ក្រុមអ្នកសំខាន់ៗ ដែលពួកគេតំ ណាងឲ្យ។

ក្រុមប្រឹក្សាសាលា ក៏ជាក្រុមអ្នកធ្វើការ ដែលទទួលខុសត្រូវក្នុងការ ធ្វើសកម្មភាព និង ការធ្វើឲ្យបានសម្រេចលទ្ធផលផ្សេងៗ។

សមាជិកពិតប្រាកដមានចំនួនខុសៗគ្នាពីក្រុមប្រឹក្សាសាលាមួយ ទៅក្រុមប្រឹក្សាសាលាមួយទៀត ប៉ុន្តែគោលការណ៍ណែនាំទូទៅគឺដូចគ្នា។

ក្រុមប្រឹក្សាសាលាទាំងអស់មានសមាជិកដែលអាចបោះឆ្នោតពី ៧ ទៅ ២១ នាក់ សមាជិកទាំងនោះរួមមាន៖

- នាយកសាលា
- យ៉ាងហោចណាស់មានបុគ្គលិកសាលា២នាក់
- សមាជិកម្នាក់មកពីសហគមន៍ (ឬ លើសពីម្នាក់) តំណាងអង្គការជាដៃគូរបស់សាលា
- មាតាបិតាដែលមានចំនួនភាគច្រើន (៥១% ឬលើសពីនេះ) នៅក្នុងក្រុមប្រឹក្សាសាលា
- យ៉ាងហោចណាស់ត្រូវមានសិស្ស ៣ នាក់ នៅវិទ្យាល័យ (សម្រាប់សាលាបឋមសិក្សា និងអនុវិទ្យាល័យ មានក៏បាន គ្មានក៏បាន)

នៅពេលបង្កើត ក្រុមប្រឹក្សាសាលា ជាលើកដំបូង សាលារបស់លោកអ្នកត្រូវសម្រេចអំពីសមាសភាពពិតប្រាកដ។ នៅពេលដែល ក្រុមប្រឹក្សាសាលា របស់ លោកអ្នកបានកើតឡើងហើយ ក្រុមប្រឹក្សាសាលានឹងមានឱកាសពិនិត្យមើលការសម្រេចចិត្តនេះជាថ្មីឡើងវិញ ហើយអាចធ្វើការកែតម្រូវ។

សមាជិកក្រុមប្រឹក្សាសាលា ដែលគេបានបោះឆ្នោតជ្រើសរើស (លើកលែងតែ នាយកសាលា និងប្រធាននៃសមាគម មាតាបិតា និង សាលា ក្នុងករណីដែលមាន) ត្រូវជ្រើសរើសទៅតាមរយៈវិធីប្រជាធិបតេយ្យ ហើយត្រូវបម្រើតួនាទីនេះសម្រាប់រយៈពេលពីរឆ្នាំ។ សូមមើលវ៉ិបសៃ www.philasd.org/sac ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីវិធីចូលជា សមាជិក និងការជ្រើសរើស ក្រុមប្រឹក្សាសាលា ហើយបំពេញលិខិតជ្រើសរើសបេក្ខជនឲ្យឈរឈ្មោះ ដើម្បីចូលរួមជាក្រុមប្រឹក្សាសាលានៅសាលារបស់លោកអ្នក។

បុគ្គលឯទៀតក៏គេស្វាគមន៍ឲ្យចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាសាលាដែរ ប៉ុន្តែមានតែសមាជិកទេដែលអាចធ្វើការសម្រេចចិត្ត និងគ្រប់គ្រងរបៀបវារៈនៃអង្គប្រជុំបាន។



## ទស្សនៈវិស័យ

ទស្សនៈវិស័យ មានអនុភាពពិតប្រាកដក្នុងការប្រមូលបុគ្គលដែលមានលក្ខណៈខុសៗគ្នា បង្រួបបង្រួមពួកគេ តាមរយៈគោលបំណង និង ការប្តេជ្ញាចិត្ត តែមួយ។ ទស្សនៈវិស័យជួយបើកឲ្យមានគំនិតឆ្នៃប្រឌិត បង្កើតឲ្យមានទិសដៅ និងធ្វើឲ្យយើងមានឋាមពល ដើម្បីធ្វើសកម្មភាព និងទទួលបានលទ្ធផល។ ទស្សនៈវិស័យ ជួយយើង ឲ្យផ្តោតលើការខំប្រឹងប្រែងរបស់យើង រក្សានូវកម្លាំងចិត្ត ហើយអាចឲ្យយើងវាយតម្លៃការរីកចម្រើនរបស់យើងបាន ជាបន្តបន្ទាប់។ ទស្សនៈវិស័យដូចគ្នា ក៏អាចជួយឲ្យយើងតម្រែតម្រង់កិច្ចការរបស់យើង និង បោះជំហានទៅតាមដំណាក់កាលជាក់លាក់ជួយគ្នាទៅវិញទៅមក និង បង្កើតកិច្ចសំខាន់មួយដែលចាំបាច់សម្រាប់ការផ្លាស់ប្តូរពិតប្រាកដ និងប្រកបដោយនិរន្តរភាព។

ក្រុមប្រឹក្សាសាលា គឺជាវិធីដ៏ល្អឥតខ្ចោះសម្រាប់រំលាយគំនិតយោបល់ និង ទស្សនៈ ដែលមិនស្របគ្នា ឲ្យទៅជាទស្សនៈតែមួយ ដែលរួមបញ្ចូលគ្នា និង គាំទ្រ ដោយសហគមន៍សាលាទាំងមូល។ ហើយការផ្តល់ទស្សនៈវិស័យតែមួយនេះ ក្រុមប្រឹក្សាសាលានឹងផ្តល់ការគាំទ្រសម្រាប់សកម្មភាព ពីការដឹកនាំបង្កើតផែនការអនុវត្ត ទៅការរកជំនួយការបង្កើតសម្ព័ន្ធភាព ខាងក្នុង និង ខាងក្រៅ និង ការបង្កើតការសហការ ដែលអាចជួយធ្វើឲ្យទស្សនៈប្រែក្លាយទៅជាការពិត។

## ពី ខ្ញុំ ទៅ យើង

ដើម្បីទាក់ទាញអ្នកដ៏ទៃសម្រាប់សកម្មភាព និង ជាម៉ាស៊ីនដឹកនាំការងារ ក្រុមប្រឹក្សាសាលាត្រូវសាមគ្គីគ្នា និងធ្វើការជាក្រុម។ ហើយក្នុងខណដែលការសហការគ្នា អាចធ្វើឲ្យមានការរំភើបចិត្ត និង ការសប្បាយរីករាយ ភាគច្រើនយើងត្រូវការការងារ និង ការប្តេជ្ញាចិត្ត ពិតប្រាកដ ទើបអាចធ្វើទៅបាន។ ដោយសារយើងខ្ញុំចង់ឲ្យលោកអ្នកមានបទពិសោធន៍វិជ្ជមាន និង ស្វាហាប់ យើងខ្ញុំសុំឲ្យសមាជិកក្រុមប្រឹក្សាសាលាទាំង អស់ កាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់សមាជិកក្រុមប្រឹក្សាសាលា ក្នុងជំហានដំបូង និងជាការតម្រូវជាមុននៅពេលចូលរួមជា មួយក្រុមប្រឹក្សាសាលា។

ការប្តេជ្ញានេះជួយយើងឲ្យស្វែងយល់ពីវិធីដែលយើងអាចប្តូរពីការផ្តោតលើខ្លួនឯង គំនិតផ្ទាល់ខ្លួន និងគោលបំណងផ្ទាល់ខ្លួន ឲ្យក្លាយទៅជាផ្នែកមួយនៃក្រុម និងគាំទ្រអត្តសញ្ញាណរបស់ក្រុម គំនិតរបស់ក្រុម និង គោលបំណងរបស់ក្រុម ដែលជាមូលដ្ឋាននៃការបង្កើតក្រុមប្រឹក្សាសាលាដ៏ប្រសិទ្ធិភាព។

